4/29/2019

# ចិនមានផែនការរឹបអូសទ្រព្យសម្បត្តិប្រទេស UGANDA ដោយសារមិនអាចដោះបំណុលរាប់ពាន់លានដុល្លារ



ឡូន បូរិន

រដ្ឋាភិបាលនៃប្រទេស Uganda
ពេលនេះកំពុងប្រឈមនឹងការបាត់បង់នូវទ្រព្យសម្បត្តិជាតិធំៗដោយសារតែខ្លួនកំពុងលង់ជំពាក់បំណុលរដ្ឋាភិបាលចិនដែលមិនអាចបង់សងវិញបាន។

យ៉ាងណា មន្ត្រីរដ្ឋាភិបាល Uganda អះអាងថា ស្ថានភាពបំណុលបរទេសនៃប្រទេសលោក មិនមានហានិភ័យធ្ងន់ធ្ងរទេ។ តែបែបនេះក្តី សារព័ត៌មាន African Stand បានចុះផ្សាយថាមិនមានតែ ប្រទេសUgandaមួយទេ ប្រឈមនឹងការរឹបអូសទ្រព្យសម្បត្តិដោយសារលង់ខ្លួនក្នុង បំណុលចិនគឺមានប្រទេសច្រើនទៀតនៃទ្វីបអាហ្វ្រិក។

កញ្ញា ឆោម ពៅនិកា ជូនសេចក្តីប្រែសម្រួល !

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនៃប្រទេសUganda លោកMatia Kasaija ប្រាប់សារព័ត៌មាន African Stand ថាប្រទេសរបស់លោកនៅបន្តស្តារប្រាក់បំណុលបាននៅឡើយទេគឺមានន័យថា មិនទាន់ដល់អស្ថិរភាពសេដ្ឋកិច្ចឡើយ។ តាមសារព័ត៌មាន African Stand ប្រទេស Uganda ជាប់បំណុលចិនប្រហែល៣ពាន់លានដុល្លារអាមេរិក។

សារព័ត៌មានដដែលបានបន្តថា មានប្រទេសច្រើនទៀតកំពុងលង់ខ្លួននឹងបំណុលចិនពាន់លានដុល្លារ។ ដោយសារដូចនេះ  កំពង់ផែសមុទ្រនៃប្រទេសកេនយ៉ាគឺកំពង់ផែម៉ុមបាសា

កំពុងប្រឈមនឹងការរឹបអុស ដោយក្រុងប៉េកាំង  ប្រសិនបើ ប្រទេសនេះគ្មានលទ្ធភាព បង់សងការប្រាក់និងប្រាក់ដើមទៅតាមពេលវេលាកំណត់មួយ។

សារព័ត៌មានអន្តរជាតិដដែលនោះចុះផ្សាយទៀតថា បើពិនិត្យលើស្ថានភាពប្រទេសក្រីក្រដែលជំពាក់បំណុលចិន ត្រូវបានគេសង្កេតថា តួនាទីរបស់រដ្ឋាភិបាលចិនប្រៀបបានជាបងធំហើយ ចិនមិនតែប៉ុណ្ណោះចិនបន្តបញ្ជូនកម្មកររបស់ពួកគេមកទាញយកអត្ថប្រយោជន៍បរិស្ថាន ដូចរ៉ែ មាស ទង់ដែង ត្បូង ប្រាក់ ពេជ្រ យកទៅប្រទេសខ្លួន ហើយបន្តបណ្តុះឱ្យអ្នកនយោបាយក្នុងប្រទេសប្រព្រឹត្តអំពើពុករលួយដើម្បីងាយខ្លួនគ្រងគ្រប់។

កាលពីឆ្នាំ២០១៧ សារព័ត៌មានអាមេរិក the New York Times ហៅករណីមួយនៅស្រីលង្កាថាជាឧទាហរណ៍មួយ ដែលចិនប្រើប្រាស់បំណុលនិងជំនួយវាយកឥទ្ធិពលក្នុងពិភពលោក ។

តាមការកត់សម្គាល់ បំណុលជាតិ ប្រទេស Uganda គឺចាប់ពីខែមិថុនាឆ្នាំ 2017 ដល់ឆ្នាំ 2018 បានកើនឡើងពី 9,1 ពាន់លានដុល្លារទៅ 11,1 ពាន់លានដុល្លារ។ របាយការណ៍សម្ងាត់មួយដោយមិនបញ្ជាក់ឈ្មោះប្រទេសចិន បានព្រមានអំពីបំណុលធំៗកំពុងគម្រាមទ្រព្យសម្បត្តិនិង អធិបតេយ្យ ប្រទេស Uganda ។ ថែមទៅទៀតនោះ របាយការណ៍នោះសរសេរថា នៅក្នុងប្រាក់កម្ចីខ្លះគឺ Uganda បានយល់ព្រមលះបង់អធិបតេយ្យភាពលើទ្រព្យសម្បត្តិប្រសិនបើខ្លួនបានប្រាក់កម្ចី។   ចិនគឺជាប្រទេសផ្តល់ប្រាក់កម្ចីធំបំផុតរបស់ប្រទេស Uganda ដែលមានប្រមាណ 3 ពាន់លានដុល្លារក្នុងគម្រោងដំបូង គឺជាប្រាក់កម្ចីក្នុងគម្រោងអភិវឌ្ឍន៍ប្រទេស ហើយប្រាក់កម្ចីនេះ តាមរយៈធនាគាររដ្ឋនៃប្រទេសចិន។

កាលពីខែធ្នូឆ្នាំ 2017 រដ្ឋាភិបាលស្រីលង្កាដែលស្ថិតក្រោមការដឹកនាំរបស់បុរសខ្លាំង មាហិនដារ៉ាជាប៉ាសេ ធ្លាក់ក្នុងបំណុលពាន់លានដុល្លារបានសម្រេចប្រគល់កំពង់ផែ Hambantota របស់ខ្លួនទៅកាន់ប្រទេសចិនក្នុងកិច្ចសន្យាជួល រយៈពេល 99 ឆ្នាំគឺបន្ទាប់ពីបរាជ័យមិនអាច ទូទាត់ប្រាក់កម្ចីរាប់ពាន់លានដុល្លារ។

ធនាគារ Exim របស់ប្រទេសចិនបានផ្តល់មូលនិធិប្រហែល 85 ភាគរយនៃគម្រោងថាមពល Uganda ចំនួនពីរគឺទំនប់ Karuma និង Isimba ។ ធនាគារនេះក៏បានផ្តល់ហិរញ្ញប្បទាននិងសាងសង់ផ្លូវHigh Way  Entebbe Express នៃទីក្រុងKampala ដែលមានតំលៃ 476 លានដុល្លារ។ ផ្លូវទំនើបនេះភ្ជាប់ព្រលានយន្តហោះរបស់ប្រទេស។  សាជីវកម្មប្រេងកាតជាតិរបស់ប្រទេសចិន  ក្រុមហ៊ុនប្រេងTotal របស់ប្រទេសបារាំង ក្រុមហ៊ុនប្រេង Tullow Oil របស់អូស្ត្រាលីសុទ្ធតែមានក្នុងភាគហ៊ុនប្រេងជាមួយ Uganda ។ អ្នកសេដ្ឋវិទូ អន្តរជាតិ Fred Muhumuza ព្រមានថា ចិនមាននៅក្នុងភាគហ៊ុនប្រេងនៃប្រទេស Uganda អាចនាំអោយចិន ចាប់យកជារបស់ខ្លួន ប្រសិនបើ ការទូទាត់បំណុលសងចិនមិនអាចទៀងទាត់។

មិនមានតែបណ្តាប្រទេសនៅអាហ្វ្រិកនោះទេធ្លាក់ក្នុងបំណុលចិន ក្រោមគំរោងអភិវឌ្ឍខ្សែក្រវ៉ាត់មួយផ្លូវមួយ (One Belt one Road) គឺប្រទេសនៅអាមេរិកដូចជាវេណេហ្សូអេឡា ក្រោមការដឹកនាំរបស់បុរសខ្លាំងនីគូឡាសម៉ាឌូរ៉ូ ដែលសេដ្ឋកិច្ចនិងការដឹកនាំកំពុងឈានដល់ការដួលរំលំក៏ធ្លាក់ក្នុងបំណុលចិនជាង៧០ពាន់លានដុល្លារ។ ចំណែកប្រទេសមួយចំនួននៅអាស៊ី ដូចជាស្រីលង្កា កោះម៉ាល់ឌីវ និងប៉ាគីស្ថាន កំពុងលង់ខ្លួនដោយសារបំណុលចិន។ ដោយឡែកប្រទេសម៉ាឡេស៊ី ស្ថិតក្រោមការដឹកនាំរបស់អតីតនាយករដ្ឋមន្ត្រីណាជីបរ៉ាហ្សាក់មានរឿងអាស្រូវ ពុករលួយរាប់រយលានដុល្លារក៏បានធ្លាក់ក្នុងគំរោងអភិវឌ្ឍន៍ខ្សែក្រវ៉ាត់មួយផ្លូវមួយរបស់ចិននូវទឹកប្រាក់ជាង២០ពាន់លានដុល្លារ។ តែនាយករដ្ឋមន្ត្រីថ្មីរបស់ប្រទេសនេះ លោកមហាធាបានសម្រេចលុបចោលគំរោងនេះ ព្រោះតែមានហានិភ័យនៃប្រាក់បំណុល។ យ៉ាងណាមានប្រទេសមួយចំនួនទៀតនៅអាស៊ីកំពុងមានមោទនភាពនៃការចាយវាយប្រាក់កម្ចីពីប្រទេសដែលគេថាពុំសូវមានតម្លាភាពនៃការគ្រប់គ្រង។ សម្រាប់ចិនបានបដិសេធដាច់ខាត ចំពោះការចោទថាចិន បង្កើត គំរោងអភិវឌ្ឍន៍ខ្សែក្រវ៉ាត់មួយផ្លូវមួយគឺជាការរាតទីនិយម ៕